**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០ សសរ

# សេចក្តីសម្រេច

**ស្តីពី**

**ការរៀបចំ និងសម្របសម្រួល «វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៤»**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ :-**

ត្រូវបានចាត់តាំងឥស្សរជនជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ជា «**គណៈដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៤**» ឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល ការត្រៀមរៀបចំ និងការដឹកនាំ «**វេទិកាលើកទី៤**» នេះ ដែលនឹងប្រព្រឹត្តទៅ នាថ្ងៃទី ២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ខាងមុខនេះ ÷

- ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជា **ប្រធានវេទិកា**
- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជា **ប្រធានរងវេទិកា**
- ឯកឧត្តម **ឈាវ យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជា **អគ្គលេខាធិការវេទិកា**

**ប្រការ ២ :-**

ក្នុងក្របខ័ណ្ឌនៃការសម្របសម្រួលការត្រៀមរៀបចំនិងដឹកនាំវេទិកាលើកទី៤នេះ **គណៈដឹកនាំវេទិកា** តាមរយៈ **ប្រធានវេទិកា** ត្រូវសហការជាមួយនឹងប្រធាននៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឱ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសម្របសម្រួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣ :-**

**ប្រធានវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូន **សម្តេច នាយករដ្ឋមន្ត្រី** អំពីវឌ្ឍនភាពនៃការរៀបចំវេទិកាលើកទី៤ និងឯកសារចាំបាច់ ដើម្បីដាក់ជូន **សម្តេច នាយករដ្ឋមន្ត្រី** ពិនិត្យផ្តល់អនុសាសន៍ និងអនុបតិ មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤ :-**

ក្នុងការត្រៀមរៀបចំវេទិកាលើកទី៤ **អគ្គលេខាធិការវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ពីវឌ្ឍនភាពការងារជូន **ប្រធានវេទិកា** និង **ប្រធានរងវេទិកា** ដោយត្រូវប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ប្រធានវេទិកានិងប្រធានរងវេទិកា និងអគ្គលេខាធិការវេទិកា ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :-**

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃព្រះហត្ថលេខារហូតដល់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៤ បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

**សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន**